Reading Book

# ពិភពរឿងនិទាន

# The World of Stories



# បុរសស្មៅកន្ត្រើយ

# The Burr Men

សៀវភៅជាឃ្លាំងនៃចំណេះដឹង

**Books are the source of knowledge**



កាលពីព្រេងនាយ មានក្មេងប្រុសពីរនាក់ ម្នាក់ឈ្មោះ **សុខ** និងម្នាក់ទៀតឈ្មោះ **សៅ** ជាកូនអ្នកស្រុកភូមិជាមួយគ្នា។ **សៅ** ជាមនុស្សចិត្តអាក្រក់ណាស់ បើបានទៅលេងជាមួយនរណាហើយ គេតែងតែរករឿងឈ្លោះប្រកែកគ្នាមិនដែលខាន។ ម្ដាយឪពុករបស់ **សៅ** ចូលចិត្តនិយាយកាន់ជើងកូនណាស់ បណ្ដាជនក្នុងភូមិខឹងហើយស្អប់នឹង **សៅ** ពន់ពេក។ ចំណែក **សុខ** ជាក្មេងកំព្រាស្លូតត្រង់រស់នៅជាមួយជីដូនចាស់ជរាក្រលំបាកក្រៃពេក។ បើ **សុខ** ទៅលេងជាមួយក្មេងៗក្នុងភូមិ ពុំដែលឈ្លោះប្រកែកគ្នាម្ដងណាឡើយ។ បណ្ដាជនក្នុងភូមិ អាណិតស្រលាញ់ **សុខ** ហើយគេតែងតែឱ្យនំចំណីមិនដែលខាន។ ម្ល៉ោះហើយ **សៅ** ក៏កើតចិត្តច្រណែន ហើយខឹងមួម៉ៅក្ដៅចិត្តកាន់តែកាចឡើងៗ គេចេះតែដើរជេរវាយកូនគេឥតញញើតដៃ ចាស់ៗឈ្លោះប្រកែកគ្នាព្រោះតែកាន់ជើងកូនរៀងខ្លួន។

Once upon a time, there were a boy whose name was SOK and another boy SAO living in the same village. SAO was a malevolent boy who usually argued with every one when he played with them. His parents spoiled him so much that the villagers felt very angry and hated him. While SOK was a polite orphan, living with his poor old grandma. When playing with the village boys, SOK never had any argument with them. The villagers were so fond of SOK that they often gave cake and food to him. Thus that deed made SAO feel jealous and angry and he was even vicious. He always made trouble and hit the other children in the villagers. So the parents had arguments because of spoiling their children respectively.



លុះ **សុខ** និង **សៅ** ចំរើនវ័យធំឡើង។ **សៅ** ក៏ទៅបបួល **សុខ** ថា "វើយ! យើងនាំគ្នាទៅកាប់ដើមឫស្សីធ្វើរនាប ត្បិតផ្ទះរបស់ឯងបាក់ពុកអស់ទៅហើយ។ **សុខ** ឆ្លើយថា "ខ្ញុំគ្មានកាំបិតមុតមាំទេ ហើយក៏គ្មានអង្គរត្រីសាច់ផងដែរ"។ **សៅ** ប្រាប់ **សុខ** ថា "មិនបាច់យកអ្វីទេ ខ្ញុំធានាយកទាំងអស់ ឯងមានតែខ្លួនទៅបានហើយ" **សុខ** ក៏និយាយប្រាប់ជីដូនថា "លោកយាយ! **បងសៅ** គាត់បបួលខ្ញុំទៅកាប់ឫស្សីល្មួសរនាបមកជួសជុលផ្ទះយើង ចំណែកបាយទឹកនៅលើគាត់ទាំងអស់"។ ជីដូនឃាត់ចៅថា "ចៅកុំទៅព្រៃឫស្សីនោះអី ព្រោះទីនោះស្ងាត់ណាស់"។ ចៅឆ្លើយថា "មិនអីទេលោកយាយ! ផ្ទះយើងពុកបាក់អស់ទៅហើយ បើបានរនាបមកគ្រាន់នឹងជួសជុលកុំឱ្យយាយផុងជើងណាយាយ"។ យាយក៏ផ្ដាំ **សៅ** ថា "ចៅទៅក៏ទៅចុះ តែ **ចៅសៅ** ឯងមើលថែទាំប្អូនផង" ហើយពួកគេក៏លាលោកយាយចេញទៅ។



When they grew up, SAO went to meet SOK and entreated, "Hey! Let's go to cut the bamboos to make lattices for your house, because it is decayed." "I don't have a sharp knife and rice, fish and meat as well," SOK replied."I do. You don't need to have them; you can go with nothing," SAO told SOK. "Grandma, brother SAO invited me to cut the bamboo trees for the lattice to repair our house," SOK told his grandma, "and he is responsible for food." "Don't go to that forest because it is quiet," Grandma dissuaded."Don't worry, grandma," Grandson replied, "our house is old and decayed. With the bamboo lattices, we can replace the old ones so that you won'step down and hurt your feet."" Ok, so you can go and grandson SAO, please take care of your younger brother," Grandma requested SAO. Then, they both left the grandma.





លុះទៅដល់ព្រៃឫស្សី បន្ទាប់ពីកាប់បានឫស្សីល្មមគ្រប់គ្រាន់ហើយ ពួកគេក៏នាំគ្នាល្អួសជារនាប។ បន្ទាប់មក ពួកគេក៏ឈប់សម្រាកបរិភោគបាយទាំងពីរនាក់ដោយអង្គុយទល់មុខគ្នា។ **សៅ** គិតថា "ជីវិត **អាសុខ** ឯងមុខជាស្លាប់ឥឡូវនេះ" គិតហើយ **សៅ** ក៏ហូតកាំបិតបន្ទោះចាក់ភ្នែក **សុខ** ដែលកំពុងហូបបាយ។ **សុខ** ស្រែកយំឈឺចាប់ជាខ្លាំង "ហេតុអ្វីក៏បងចាក់ភ្នែកខ្ញុំ?" **សៅ** ប្រាប់ថា "ឯងស៊ីបាយអញហើយ ចង់យករនាបអញទៀត"។ **សុខ** ឆ្លើយថា "កាលបងបបួលខ្ញុំ ខ្ញុំបានប្រកែកថា ខ្ញុំគ្មានអ្វីទេ តែបងធានាថាមានគ្រប់ទាំងអស់បានជាខ្ញុំមក ឥឡូវបើបងចង់បានរនាបនេះ សូមបងយកទៅចុះ តែបងកុំសម្លាប់ខ្ញុំអី"។ **សៅ** សំឡុតថា "ឯងនេះមាត់រឹងណាស់ ឆាប់ភាវនាធម៌ទៅ" ថាហើយ **សៅ** លើកកាំបិតបន្ទោះចាក់ភ្នែក **សុខ** ម្ខាងទៀតឈាមស្រក់ពេញមុខ។ ធ្វើឱ្យភ្នែក **សុខ** ងងឹតទាំងសងខាង ណាស្តាយជីវិត ណាអាណិតជីដូននៅឯផ្ទះ។ **សៅ** និយាយថា "អញទម្លាក់ឯងទៅឱ្យត្រីស៊ីចុះ"។ ថាហើយ **សៅ** ធាក់ **សុខ** ទម្លាក់ចូលទៅក្នុងទឹកស្ទឹងដែលកំពុងតែហូរខ្លួលខ្លាញ់។

When they arrived in the bamboo forest, they cut the bamboo trees and stripped them into lattices. Then, they sat face to face having lunch. "SOK, your life is going to end right now," SAO thought. He took out the curved sharp knife and thrusted it into one of SOK's eyes, who was having meal. "Why did you thrust into my eye?" SOK cried with pain. "You not only eat my meal but also want to take my lattices," SAO answered. "When you persuaded me," SOK replied, "I told you I had nothing, but you guaranteed for every thing if I came with you. Now you can take the lattices if you want; please don't kill me.""You are very stubborn, please meditate for the Dharma before you die," SAO shouted and then he took the knife and poked into the other one of SOK's eyes. The blood quickly shed on SOK's face. SOK was blind; he was regretful with his life and felt pity for his grandma, who was at home alone. "I'll throw you into the river for fish's prey," SAO said. After that SAO kicked SOK into the river which was flowing very fast.

**សៅ** គិតថា **សុខ** ស្លាប់បាត់ហើយ ក៏ប្រមូលរនាបទាំងអស់ចងបាច់ ត្រលប់ទៅផ្ទះវិញ។ ហើយហួសទៅកុហកជូនចាស់ថា "លោកយាយ! ខ្លាខាំ **អាសុខ** ស្លាប់បាត់ទៅហើយ"។ **សៅ** សប្បាយចិត្តណាស់ដើរលេងជិតៗផ្ទះដូចធម្មតាដោយចិត្តក្លាហានរកតែរឿងឈ្លោះគេដដែល។ ចំណែកជូនចាស់ពេលឮ **សៅ** និយាយដូច្នេះ ក៏យំសោកបោកខ្លួនហៀបនឹងក្ស័យជីវិត "ចៅជីដូនស្ងួននៅឯណា? យាយសែនខ្លោចផ្សាពេលមិនឃើញចៅមក"។

SAO thought that SOK was dead so he collected all bamboo lattices and went back home. He went over to the grandma's house and told lie, "Grandma, SOK has been eaten by a tiger." SAO was happily walking nearby his home as usual and his deed of aggression was still the same. After grandma heard this news, she cried nearly dying. "Grandson, where are you? I am painful when not seeing you," Grandma sobbed.



និយាយពី **សុខ** ហែលបណ្តែតខ្លួនតាមខ្សែទឹកហូរ ហើយភាវនារក តែពុទ្ធោៗមិនដាច់ពីមាត់។ លុះហែលទៅដល់អាស្រមឥសីមួយនៅមាត់ស្ទឹង ឥសីនោះមានមហិទ្ធិរិទ្ធិខ្លាំងពូកែណាស់ ជាមួយនឹងក្រពើដែលកំពុងដេក នៅក្រោមអាស្រមឥសី វាអាចតំណែងខ្លួនជាមនុស្សបានទៀតផង។

Talking about SOK, he swam on the surface of the flowing water, meditating the Buddhist words "Puthor! Puthor" without stopping. At last he got to a hut of a hermit near the riverbank. The hermit was very magically powerful and had two big crocodiles sleeping under his hut. The two crocodiles could transform them selves to be human.



ពេលក្រពើឃ្លានអាហារ វាស្ទុះចុះទៅក្នុងទឹកស្ទឹងក៏ប្រទះឃើញមនុស្សកំពុងហែលបណ្តែតខ្លួនតាមខ្សែទឹកហូរ ។ ក្រពើគិតថា "ថ្ងៃនេះមានលាភធំណាស់បានសាច់មនុស្សស៊ីម្តងហើយ" ក្រពើហែលទៅជិតឮសម្លេងពុទ្ធោៗក៏សង្ស័យក្នុងចិត្ត ហើយមើលទៅភ្នែក **សុខ** ទាំងពីរផ្លុះរកប្រស្រីគ្មាន។ ក្រពើគិតថា "អញគួរតែយកគេទៅថ្វាយលោកតា អញមិនគួរស៊ីមនុស្សកំសត់នេះទេ"។ ហើយក៏មុជទឹកកៀង **សុខ** មកដល់លើគោក។ ក្រពើតំណែងខ្លួនជាមនុស្សដឹកដៃ **សុខ** ទៅថ្វាយលោកតា។ ឥសីសួរ **សុខ** អំពីរឿងដែលបានមកដល់អាស្រម។

When the crocodiles were hungry, they rushed into the river and discovered a man swimming on the flowing water. The crocodiles thought, "We are very lucky today that we have the human flesh for eating one time. When the crocodiles swam nearer to the man, they heard the voice, "Puthor! Puthor! " They were suspicious and saw the man's eyes have no irises. "We should take them to our hermit; we should not eat this pitiful man," thought the crocodiles. Then they swam to push SOK to the land. The crocodiles transformed themselves to be human and held SOK's hands towards the hermit. The hermit asked SOK why he arrived here.



**សុខ** ថ្វាយបង្គំឥសីតាមរឿងពិតគ្រប់ប្រការ លោកតាមានចិត្តមេត្តាដល់ **សុខ** ពន់ពេក។ ឥសីមានពុទ្ធដីការថា "ឱ **ចៅសៅ** អើយ! ហេតុអ្វីក៏ចៅចិត្តអាក្រក់ម្ល៉េះ? ណ្ហើយចុះចៅកុំព្រួយ សឹមតាជួយចៅឱ្យមានភ្នែកភ្លឺដូចដើម នឹងបានទៅជួបជីដូនវិញ"។ តាឥសីក៏ផ្សំថ្នាំដាក់ភ្នែកសូត្រមន្តទិព្វផ្លុំភ្នែក **ចៅសុខ** រហូតភ្នែកភ្លឺដូចដើម ហើយលោកបានក្តាប់ដីខ្សាច់មួយដៃសែកមន្តទិព្វផ្លុំដីខ្សាច់ដាក់បាតដៃស្តាំ **ចៅសុខ** ថា "ចៅក្តាប់ដីខ្សាច់ឱ្យជាប់កុំលាដៃឱ្យសោះ។ ចាំទៅដល់ផ្ទះ ចៅប្រាប់ជីដូនក្រាលកន្ទេលក្នុង ផ្ទះ សឹមចៅលាដៃដាក់ដីខ្សាច់នេះទៅលើកន្ទេល"។

SOK told the hermit all account of his true story. After listening to what had happened to SOK, the hermit felt extremely sympathetic. He said, "Oh! Grandson SAO, how malevolent you are! Well, don't worry. I'll help cure your eyes and you will be able to see it again so that you can go to meet your grandma." The hermit made the medicine to apply SOK's eyes, and recited magic verses and blew on his eyes until he was recovered. The hermit took a handful of sand, recited magically, and blew the sand into SOK's palm of right hand and said, "Hold this sand tightly in your hand without opening it, and when you get home, tell your grandma to lay down a mat and throw this sand onto it."



ឥសីផ្តាំរួចហើយ ក៏ប្រើក្រពើជូន **ចៅសុខ** ទៅដល់កន្លែងដែលកាប់ឫស្សី។ **សុខ** ត្រឡប់ទៅដល់ផ្ទះវិញ ហើយចូលទៅយំសំពះជីដូនៗឃើញចៅ ក៏ស្ទុះមកឱបចៅយំខ្សឹកខ្សួលលួងលោមចៅ "គេប្រាប់យាយថា ខ្លាខាំចៅស្លាប់ទៅហើយ។ ម្ចាស់ជីដូនអើយ ជីដូនយំសោកបោកខ្លួនអាសូរចៅហៀបនឹងក្ស័យជីវិត ឥឡូវចៅមិនស្លាប់ ជីដូនអរណាស់រកអ្វីប្រៀបផ្ទឹមពុំបានឡើយ"។ **ចៅសុខ** និយាយប្រាប់ជីដូនថា "ពេលចៅទៅកាប់ឫស្សីលួសរនាប **បងសៅ** បានចាក់ភ្នែកចៅធាក់ទម្លាក់ទឹក តែបានក្រពើនាំចៅទៅថ្វាយលោកតាឥសី" ជីដូនឮបែបនេះរឹតតែអាណិតចៅខ្លាំងឡើង។

After giving some advice to SOK, the hermit ordered the crocodiles to take him to the place where he cut the bamboo trees. When SOK arrived home, he cried and went to salute his grandma. When Grandma saw her grandson, she rushed to hug him. "I was told that you were eaten by a tiger," She said while sobbing, "Oh! My grandson, I sobbed and mourned nearly to die of missing you." " Now you are alive; I am so happy," she added. "When I went to cut bamboo trees for the lattices," SOK told his grandma, "Brother SAO thrusted his knife into my eyes and pushed me into the water; fortunately, the crocodiles took me to the hermit." The old lady felt even more pitiful for SOK after hearing this.





បន្ទាប់មក **សុខ** ប្រាប់ជីដូនឱ្យក្រាលកន្ទេលក្នុងផ្ទះ។ **សុខ** លាដៃចាក់ដីខ្សាច់លើកន្ទេល។ រំពេចនោះ ក៏កើតជាមាសប្រាក់គរនៅលើកន្ទេល។ ពីរនាក់ជីដូន និងចៅត្រេកអរជាអនេក បានចាត់ចែងទិញសំភារសំលៀកបំពាក់ និងសង់ផ្ទះថ្មីល្បីមានដាច់គេក្នុងភូមិ។ និយាយពី **សៅ** ឃើញ **សុខ** ក៏នឹកឆ្ងល់ក្នុងចិត្តថា "អញចាក់ភ្នែកវាធាក់ទម្លាក់ទឹកស្មានថាវាស្លាប់ ឥឡូវវានៅរស់ភ្នែកក៏ភ្លឺដូចដើម ថែមទាំងមានទ្រព្យសម្បត្តិច្រើនទៀត"។ លុះដល់វេលាស្ងាត់ **សៅ** ស្កាត់មកជួប **សុខ** និយាយថា "កាលឯង និងខ្ញុំទៅកាប់ឫស្សីនោះ បិសាចបានមកសណ្ឋិតរូបខ្ញុំទេ គេឱ្យខ្ញុំចាក់ភ្នែកឯងទាំងសងខាង ហើយធាក់ឯងទម្លាក់ទឹកខ្ញុំស្មានថាឯងស្លាប់បាត់ទៅហើយ ហេតុដូចម្តេចបានជាឯងនៅរស់ ហើយមានទាំងទ្រព្យច្រើនជាងគេយ៉ាងនេះ?" **សុខ** ឆ្លើយថា "បានគុណបងកុំអីខ្ញុំក្រលំបាកវេទនារហូតហើយ ដូចបងឃើញស្រាប់ កាលដែលបងច្រានខ្ញុំធ្លាក់ចូលទឹកស្ទឹង ខ្ញុំបណ្តែតខ្លួនតាមបណ្តោយខ្សែទឹកហូរ ហើយស្រែករកតែពុទ្ធោៗឥតមានឈប់។ **សុខ** ក៏បន្តការនិយាយនេះរហូតដល់ចប់។

Then SOK told his grandma to lay down the mat in the house. SOK opened his hand, pouring the sand onto the mat. Suddenly, the sand created a pile of silver and gold on the mat. Both the grandma and grandson were very happy and managed to buy stuff and clothes, built a new house and they became the most famous family in the village. As for SAO, when seeing SOK, he wondered himself, "I thrusted his eyes and kicked him into the water. Why he is not dead instead he is now alive, able to see, and even wealthier." When it was quiet, SAO went to meet SOK on his way and said, "When you and I went to cut the bamboo trees, the demon came to control me and forced me to thrust your eyes and kicked you into the water. I supposed you were dead, but why are you alive and even richer than the others?" "It is your gratitude that makes me rich;" SOK replied, "Otherwise, I may have been so poor. As you know when you pushed me into the water I floated on the water, and said the words Puthou Puthou without stopping." SOK went on telling SAO about what had happened to him to the end.



**សៅ** ឮ **សុខ** ប្រាប់ដូច្នោះ ក៏មានចិត្តលោភលន់ពន់ប្រមាណ ហើយគិតថា "អញនឹងធ្វើឱ្យបានដូច **អាសុខ**។ ក្រោយមក **សៅ** មកជួប **សុខ** និយាយថា "សម្លាញ់អើយ! ខ្ញុំចង់ទៅកាប់ឫស្សីនៅព្រៃកន្លែងមុនទៀត ឯបាយទឹកនិងសម្ភារនៅលើខ្ញុំ ឯងទៅតែខ្លួនបាន ហើយ"។ **សុខ** ឆ្លើយថា "ទេ! ខ្លាចបងសម្លាប់ខ្ញុំទៀត។" **សៅ** ប្រាប់ **សុខ** ថា "មុននោះខ្មោចកម្រោលចូលរូបខ្ញុំទេ ខ្ញុំមិនដឹងខ្លួនទាល់តែសោះ ឯងកុំប្រកាន់ខឹងនឹងខ្ញុំអី"។ **សុខ** ឆ្លើយថា "ចាំខ្ញុំជូនបងទៅ! ត្បិតបងធ្លាប់មានគុណលើខ្ញុំ ខ្ញុំមានទ្រព្យសម្បត្តិក៏ព្រោះតែបង"។ លុះព្រឹកឡើង **សៅ** ស្ពាយបាយសំណុំមានគ្រប់ប្រដាប់ដូចមុន ហើយបណ្ដើរគ្នាទៅដល់ព្រៃឫស្សី។ លុះកាប់បានច្រើនហើយក៏ពុះលួសជារនាប។ បន្ទាប់មកក៏នាំគ្នាអង្គុយបរិភោគបាយ។ ហេតុតែ **សៅ** មានចិត្តលោភលន់ចង់បានទ្រព្យសម្បត្តិ ក៏ប្រញាប់ហុចកាំបិតបន្ទោះទៅឱ្យ **សុខ** ប្រាប់ថា "ឯងចាក់ភ្នែកខ្ញុំទាំងពីរមក!" **សុខ** ប្រកែកពុំព្រមចាក់ **សៅ**ចេះតែបង្ខំដដែលៗ "ចាក់មកៗកុំខ្លាចអី" **សៅ** បង្ខំ **សុខ** ជាច្រើនដង។

SAO, hearing what SOK had said, was very greedy. "I will do as SOK did," SAO thought. Later, SAO went to meet SOK again and persuaded, "Friend! I want to cut the bamboo trees at the same place. I am responsible for meal and other equipments and you only go without anything." "No, I'm afraid that you may kill me again," SOK replied. "I won't," SAO said, "previously. the demon came to control me; I didn't know what I was doing. Please don't mind me." "I'll go with you because you were once grateful for me; I am rich because of you," SOK answered. Next morning SAO carried a bag of meal and all equipments as the previous time and walked together into the forest. After cutting many bamboo trees, they stripped them into lattices and then had meal. Because of his greed for wealth, SAO passed his knife to SOK and said, "Thrust it into my two eyes." SOK refused to thrust SAO but he forced SOK again and again. "Thrust me! Thrust me! Don't be scared," SAO ordered.

**សុខ** ក៏ចាក់ភ្នែក **សៅ** ខ្វាក់ទាំងសងខាង។ **សៅ** ឈឺពើតខ្លាំងណាស់ តែព្រោះចង់បានប្រាក់ ក៏ឱ្យ **សុខ** ច្រានខ្លួនទម្លាក់ទឹកស្ទឹងដែលកំពុងហូរ។ **សៅ** ប្រឹងស្រែកពុទ្ធោៗមិនដាច់ពីមាត់ ក្រែងបានជួបនឹងក្រពើ។ **សៅ** ឈឺភ្នែកជាខ្លាំង នៅតែខំហែលបណ្ដែតខ្លួនទៅមុខទៀត។ យូរៗទៅ **សៅ** អស់កម្លាំងឈ្លក់ទឹកស្លាប់នៅក្នុងទឹកស្ទឹងបាត់ទៅ។ ហើយសាច់ស្អុយរលេះរលួយ មានត្រីជាច្រើនដណ្ដើមសាច់គ្នាស៊ីជាអាហារ សល់តែលលាដ៍ក្បាលអណ្ដែតតាមទឹកស្ទឹង។

SOK, then, thrusted into SAO's both eyes. SAO was getting blind and painful in his eyes; but due to his greed for money, he asked SOK to push him into the flowing river. SAO tried to say *Puthou Puthou* without stopping in the aim of meeting the crocodiles. SAO was very painful in his eyes; however he floated himself on the flowing water ahead. Longer and longer, SAO was exhausted and drowned to death in the river. His flesh was rotting. Many fishes came to pick up his flesh for eating until it was all and there was the skull left , floating on the water.



ទោះបីលលាដ៍ក្បាលខ្មោច **សៅ** អស់សាច់សល់តែឆ្អឹងក៏ដោយ ក៏ព្រលឹងរបស់គេនៅតាមលលាដ៍លងមនុស្សឮតែពុទ្ធោៗរហូត ដរាបទៅដល់កំពង់ទឹកមហាសេដ្ឋី។ វេលានោះកូនក្រមុំសេដ្ឋី នាំបរិវារប្រុសស្រីចុះងូតទឹក កំពុងតែលេងទឹកយ៉ាងសប្បាយ ស្រាប់តែឃើញលលាដ៍ក្បាលខ្មោចនោះអណ្តែតមកជិត លងគេស្រែករកពុទ្ធោៗ។ ពួកគេឈប់លេងទឹកទាំងអស់គ្នា កូនក្រមុំសេដ្ឋីក៏ប្រើខ្ញុំប្រុសម្នាក់ឱ្យទៅស្រង់យកលលាដ៍ខ្មោចមកដាក់លើគោក លលាដ៍ខ្មោចនោះចេះតែរកពុទ្ធោៗជានិច្ច។

Though there was no flesh but the skull, his soul was always with his skull, haunting people by expressing the voice *Puthou Puthou* until it arrived at a millionaire's port. While the daughter of the millionaire was swimming happily together with her menservants and women servants, they saw the skull floating near and haunting them by making the voice *Puthou Puthou*. They all stopped swimming and the millionaire's daughter ordered a manservant to go and pick it up to the land. The skull remained saying *Puthou Puthou*.





កូនក្រមុំមហាសេដ្ឋី ឱ្យខ្ញុំប្រុសកាន់លលាដ៍ខ្មោចមកផ្ទះជម្រាបឪពុកថា "លោកពុកៗ! កូនរើសបានលលាដ៍ក្បាលខ្មោចមួយអណ្តែតទឹកស្រែករក តែពុទ្ធោៗ"។ សេដ្ឋីជាឪពុកស្តាប់ហើយ ក៏ស្ទុះមកមើលឃើញមែន ក៏ឱ្យគេលាងជុសខាត់ដាក់លើគោក។ លលាដ៍ក្បាលនោះនៅតែរកពុទ្ធោៗគ្មានឈប់។ រាល់ព្រឹក សេដ្ឋីម្នាក់នេះតែងតែទៅគាល់ព្រះមហាក្សត្រនៅព្រះរាជវាំងជួបជុំអស់លោកមន្ត្រីពុំដែលខាន។ សេដ្ឋីជំរាបអស់លោកនោះថា "ខ្ញុំមានលលាដ៍ក្បាលខ្មោចមួយ ចេះតែស្រែករកពុទ្ធោៗជាប់ជានិច្ច" អស់លោកស្តាប់ហើយឆ្លើយថា "លោកកុហក មិនដែលមានក្បាលខ្មោចឯណាចេះនិយាយទេ ខ្ញុំមិនជឿទេ"។ សេដ្ឋីបញ្ជាក់ទៀតថា "ពិតប្រាកដណាស់ បើអស់លោកមិនជឿខ្ញុំទេ យើងភ្នាល់ដាក់មាស១០០តម្លឹងទៅ"។ មន្ត្រីក៏យល់ព្រមភ្នាល់ជាមួយសេដ្ឋីម្នាក់នោះមែន។



The daughter of the millionaire ordered her manservant to take the skull to her house. "Dad, I found a skull floating on the water saying *Puthou Puthou*," she told her father. After hearing his daughter, the millionaire rushed to see it and it was true as what his daughter had told, so he had it washed and brought it on the land. The skull was still saying *Puthou Puthou* without stopping. Every morning the millionaire always went to see the king at the royal hall and always met the royal officials. "I have a skull, which always says *Puthou Puthou*," the millionaire told them. Having heard this, the royal officials replied, "You are telling us a lie; skull could not speak. I don't believe you."

"It is true," the millionaire answered, "If you don't believe me, we can have a bet on this for 100 Damloengs of gold." Then, the royal officials accept the bet with the millionaire.





សេដ្ឋីទៅដល់ផ្ទះ ឮលលាដ៍ក្បាលស្រែកពុទ្ធោកោកៗគិតថា "មន្ត្រីទាំងនោះមុខជាចាញ់យើងហើយ"។ សេដ្ឋីយកមាស១០០តម្លឹង ហើយប្រើក្មួយកាន់តោកដែលដាក់លលាដ៍ក្បាលខ្មោចនោះប្រញាប់ទៅយ៉ាងរហ័ស។ លុះចូលទៅដល់ក្លោងទ្វារកំផែង លលាដ៍ក្បាលខ្មោចបាត់សម្លេងឈឹង។ ពេលចូលទៅដល់ក្នុងព្រះរាជរោង សេដ្ឋីក៏ដាក់លលាដ៍ក្បាលចំពោះមុខមន្ត្រីទាំងបួននាក់នោះ ហើយបង្គាប់ថា "ចាំអីទៀត ម្ដេចក៏មិនស្រែករកពុទ្ធោៗទៀតទៅ" លលាដ៍ក្បាលខ្មោចបាត់សូន្យឈឹង មិនឮរកពុទ្ធោសោះឡើយ។ បន្ទាប់មក សេដ្ឋីក៏ចាញ់មាស១០០តម្លឹង។ អស់លោកនោះសើចចំអកថា "អ៊ូយថ្លង់ណាស់! ថ្លង់នឹងសម្លេងក្បាលខ្មោច" ហើយទះដៃសើចពេញព្រះរាជរោង។

When the millionaire arrived home, he heard the skull shouting *Puthou Puthou* loudly and thought himself, "These royal officials are going to lose the bet." The millionaire took out 100-Damloeng gold and told his nephews to hurriedly take a basket with the skull to the royal hall. When they arrived at the gate of the royal palace, the skull sounded nothing. When the skull was taken into the hall, it was put in front of the four royal officials. "Don't wait any longer, why you don't say Puthou Puthou?" the millionaire ordered the skull. The skull said nothing: the word *Puthou Puthou* was not heard and therefore, the millionaire lost 100-Damloeng gold. "Oh! It is very noisy! It is very noisy with the voice of the skull," said the official ridiculously, and they clapped their hands and laughed all over the royal hall.



សេដ្ឋីខឹងនឹងលលាដ៍ក្បាលខ្មោចនេះណាស់ លាអស់លោកចេញមក ដល់ក្រៅកំផែង ស្រាប់តែលលាដ៍ក្បាលខ្មោចនោះស្រែករកពុទ្ធោៗ សេដ្ឋីរឹតតែខឹងខ្លាំងឡើង។ លុះមកដល់ផ្ទះ ប្រើបាវឱ្យយកពូថៅសំពងលលាដ៍ខ្មោចបោះទម្លាក់ទឹកវិញ។ ឯលលាដ៍ក្បាលខ្មោច **ចៅសៅ** នោះអណ្ដែតតាមទឹកស្ទឹងហូររសាត់ទៅក្រោមរហូតទៅដល់កំពង់វត្ត។ វេលានោះព្រះសង្ឃនិមន្តទៅស្រង់ទឹក បានឃើញលលាដ៍ក្បាលខ្មោចលងរកពុទ្ធោៗ លោកក៏ស្រង់យកទៅកុដិ រួចដុតលលាដ៍នោះឱ្យសុស ហើយព្រះសង្ឃពិចារណាថា "គួរតែយកកំទេចឆ្អឹងនេះ លាយនឹងម្រ័ក្សណ៍ខ្មុកលាបសរសរព្រះវិហារ បញ្ជូនឱ្យបានមគ្គផលដល់ម្ចាស់លលាដ៍ដែលបានស្លាប់ទៅ ហើយលោកយកខ្មុកសល់បន្តិចបន្តួចយកទៅលាបលនរទេះ ហើយរង់ចាំរហូតដល់ ស្ងួត។



The millionaire was furious with the skull. He left the royal officials and came outside the wall. Suddenly, the skull said *Puthou Puthou*; the millionaire was even angrier. When he got home, he told his servants to break the skull with an ax and throw it back into the water. SAO's skull floated on the water down to a pagoda port. At that time, a monk was swimming at the port, seeing the skull haunting him with the voice Puthou Puthou. The monk took the skull to his building and burnt it into ashes. "It is nice to mix this ash with lacquer," he thought, "And apply on the temple pillars in order to send this merit to the person who had passed away. I'll use the remaining ash for coating the ox cart and wait until it becomes dry."

ថ្ងៃមួយ ព្រះអង្គនឹកភ្នកចង់ទៅសួរញាតិញោមក្នុងភូមិ លោកក៏ប្រើសិស្សដឹកគោមកទឹម ហើយបររទេះចេញទៅ។ លុះបររទេះបានឆ្ងាយបន្តិចរទេះនោះក៏លាន់ភ្លៅ និងដុំសង្គ្រៀតគ្នាដូចធម្មតា។ រហូតបានជួបឧបាសកឧបាសិកា រទេះក៏ចាប់ផ្ដើមឮសូរសម្លេងដូចលោកបញ្ចោរគេថា "មេចោរៗ" ញាប់សិញ។ ឧបាសក ឧបាសិកាឮដូច្នេះ ខឹងនឹងព្រះសង្ឃជាខ្លាំង ក៏ស្ដីថាឱ្យព្រះសង្ឃវិញមិនប្រណី។ ព្រះសង្ឃក៏បង្ខំសិស្សបររទេះទៅមុខទៀតយ៉ាងលឿន។



The monk wished to visit his relatives in the village; he told his students to yoke the oxen and rode off the ox cart. When they rode a bit further, the hubs of the cart wheels made sound as usual. But when they met the laymen and laywomen, it sounded as if it was cursing: *Mechor Mechor (the thief),* repeating very fast. Hearing this sound, the laymen and laywomen were furious with the monk and cursing the monk without saving his face. Then the monk ordered his students to go ahead faster.

បន្ទាប់មកក៏បានទៅជួបនឹងនាម៉ឺនមួយក្រុម រទេះនោះក៏លាន់ម្តងទៀត ដូចជាជេរនាម៉ឺនថា "ចោរម្តាយនាម៉ឺនៗ" ពួកនាម៉ឺនទាំងអស់នោះខឹងនឹងព្រះសង្ឃខ្លាំងណាស់ ក៏ដេញវាយលោកយ៉ាងញាប់ដៃ លោកភ័យកាន់តែខ្លាំង ខំបំបោលគោទៅមុខទៀតកាន់តែលឿន។ ព្រះសង្ឃគិតថា "រទេះអាត្មាអញពីដើមមក មិនដែលឮសូរដូច្នេះទេ រឿងនេះមានតែកំទេចឆ្អឹងលលាដ៍ក្បាលខ្មោចនេះហើយ"។



Afterwards, the monk met a group of officials. Again, the cart started another sound as if someone was cursing them in a repeated word "Chor Mday Neameun" (the officials' mothers are thieves). The officials were very angry with the monk. They chased the cart to hit the monk quickly. The monk was even more frightened and went off faster and faster. "My cart has never made this sound so far," the monk thought, "It must be out of the ash of the skull."

លុះព្រះសង្ឃត្រលប់មកដល់វត្តវិញ លោកកាប់រទេះដុតនៅទីកន្លែង ដែលដុតលលាដ៍ក្បាលខ្មោចឱ្យឆេះទៅជាផេះទាំងអស់។ **នាយសៅ** ដែលកាលពីនៅរស់ គេចូលចិត្តឈ្លោះប្រកែកគ្នា និងចូលចិត្តឈ្នានីសគេណាស់។ ដូច្នេះហើយ បានជានៅកន្លែងកំទេចផេះនោះមានជាតិ **ចៅសៅ** ក៏ដុះកើតជា **ស្មៅកន្ត្រើយ** ដែលចូលចិត្តជាប់សំពត់ខោមនុស្សសព្វ ថ្ងៃនេះ។
**ចប់**

**"ចិត្តមិនអប់រំ នាំខ្លួនវិនាស"**



When arriving at the pagoda, the monk broke off the cart and burnt it all at the same place where he had burnt the skull. When SAO was alive, he liked making arguments and envying the others. That was why the place, where there were his remains, was grown by the burr, which has always stuck on the people's skirts or trousers up to now. **The end**

**A man with no education can result in harming himself.**